**កិច្ចប្រជុំបូកសរុបលទ្ធផលសកម្មភាពការងារឆមាសទី១ ឆ្នាំ២០១៥**

**និងលើកទិសដៅអនុវត្តបន្តរបស់ក្រុមការងារថ្នាក់ជាតិ ខេត្ត ចុះជួយមូលដ្ឋាន ក្រុង ស្រុក ឃុំ សង្កាត់ ដើម្បីត្រួតពិនិត្យ**

**និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នៅសាលប្រជុំសាលាខេត្តកំពត ។**





នៅថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០១៥ នៅសាលប្រជុំសាលាខេត្តកំពត មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលសកម្មភាពការងារឆមាសទី១ ឆ្នាំ២០១៥ និងលើកទិសដៅអនុវត្តបន្តរបស់ក្រុមការងារថ្នាក់ជាតិខេត្ត ចុះជួយមូលដ្ឋាន ក្រុង ស្រុក ឃុំ សង្កាត់ ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ក្រោមអធិបតី ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត នៅសាលប្រជុំសាលាខេត្តកំពត ។

បន្ទាប់ពីគោរពភ្លេងជាតិ និងស្មឹងស្មាធគោរពវិញ្ញាណក្ខន្ធ សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត ជា ស៊ីម រួចមក ឯកឧត្តម ខូយ ឃុនហួ អភិបាលនៃគណៈអភិបាលខេត្តកំពត និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋានខេត្តកំពត បានអញ្ជើញថ្លែងសន្ទរកថាស្វាគមន៍ និងធ្វើរបាយការណ៍ ដោយបានលើកឡើងពីភាពរីកចម្រើន និង ការអភិវឌ្ឍន៍ នូវសមិទ្ធផលថ្មីៗជាច្រើន របស់រដ្ឋបាលខេត្តកំពត ដែលធ្វើឱ្យប្រជាពលរដ្ឋមានការសាទរីករាយជាខ្លាំង ។ ទាក់ទងនិងលទ្ធផលរបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត ក្រោមការដឹកនាំរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ

ក្នុងរយៈពេល ០៦ខែ ឆ្នាំ២០១៥ នេះ ឯកឧត្តមអភិបាលខេត្តបានបញ្ជាក់ថា:

ចាប់តាំងពីរាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នាថ្ងៃទី២៧ ខែ មករា ឆ្នាំ២០១៤កន្លងទៅ មកដល់ថ្ងៃនេះ មានរយៈពេលមួយឆ្នាំ បួនខែ និងម្ភៃថ្ងៃ គត់ គឺក្រុមការងារថ្នាក់ជាតិ ដែលដឹកនាំដោយឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្រេចលទ្ធផលផ្លែផ្កាជាច្រើន។ ជាក់ស្តែងការធ្វើវេទិការសាធារណៈ របស់ក្រុមការងារថ្នាក់ជាតិ ខេត្ត ចុះធ្វើតាមបណ្តាក្រុង ស្រុក និងឃុំ–សង្កាត់ ដោយផ្អែកតាមទិន្នន័យ ដែលប្រមូលបានមកពីបណ្តាក្រុង ស្រុក ឃើញថា អនុវត្តបានស្ទើរតែបានគ្រប់ឃុំ សង្កាត់ ទាំងអស់នៃខេត្តកំពត ហើយដែលគិតមកដល់ពេលនេះ ក្រុមការងារថ្នាក់ជាតិ ខេត្ត បានចុះមូលដ្ឋានផ្ទាល់ ធ្វើវេទិកាសាធារណៈ ដើម្បីស្រង់យកនូវបញ្ហាប្រឈម និងសំណូមពរពីប្រជាពលរដ្ឋ បានចំនួនសរុប ១៧៥ វេទិកា ស្មើនិង១៧៤ភូមិ ឃុំ សង្កាត់ ដែលមានប្រជាពលរដ្ឋចូលរួមចំនួន ២៦.០២៨នាក់ ស្រី ៩.៥៥២ នាក់ ។ ដោយឡែក នៅឆមាសទី១ ឆ្នាំ២០១៥ ក្រុមការងារថ្នាក់ជាតិ បានចុះធ្វើវេទិកាសាធារណៈបានចំនួន ៤៤ លើក ស្មើនិង៤៤ ភូមិ ឃុំ សង្កាត់ និងហាមានប្រជាពលរដ្ឋចូលរួមសរុបចំនួន ៥.៤៥៧ នាក់ ស្រី២.១៥៣ នាក់ ។




ព្រះរាជាណាចក្រកម្ពុជា





អំពីដំណោះស្រាយបញ្ហាប្រឈម និងសំណូមពរ ដែលយើងប្រមូលបានពីវេទិកាសាធារណៈមានចំនួន ៦២៣ រឿង ដែលក្នុងនោះមានរឿងចាស់ចំនួន៤១៧ រឿង និងរឿងថ្មីចំនួន២០៦ រឿង ហើយគិតទាំងរឿងចាស់ និងរឿងថ្មី ក្រុមការងារបានដោះស្រាយរួចចំនួន ២៧២រឿង កំពុងដោះស្រាយចំនួន ១៧១ រឿង និងលើកសំណើមកអោយក្រុមការងារថ្នាក់ជាតិ សម្រាប់ជាការដោះស្រាយមានចំនួន ១៤៩ រឿង ។ រីឯបញ្ហាប្រឈម និងសំណូមពរ ចំនួន៣១ រឿង ផ្សេងទៀតបានលើកមកហើយ ។ ប៉ុន្តែមិនឃើញមានដាក់ថ្នាក់ណាជាអ្នកដែលបាន ដោះស្រាយនោះទេ (បញ្ហានេះមាននៅស្រុកដងទុង) ។ ចំពោះបញ្ហាប្រឈម និងសំណូមពរខ្លះ ដែលមានពីមុនមក យើងបានស្នើសុំទៅថ្នាក់ជាតិបានចំនួន ២១ រឿង រួចហើយ ។

មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានកោតសរសើរនិងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធររដ្ឋបាលខេត្តកំពត ក្នុងការដឹកនាំអភិវឌ្ឍន៍ខេត្តឱ្យមានការរីកចម្រើនគួរមោទនះ និងថ្លែងការកោតសរសើរ ចំពោះក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត ដែលបានអនុវត្តការងារស្នូលរបស់ខ្លួនប្រកបដោយលទ្ធផលផ្លែផ្កា ដោយបានចុះស្ទើរគ្រប់មូលដ្ឋានគោលដៅរបស់ខ្លួន ដើម្បីក្តាប់សំណូមពរនិង ដោះស្រាយ បកស្រាយ បញ្ហានានា

ដែលជាកង្វល់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
និងចងក្រងជាកញ្ចប់បញ្ហាសម្រាប់ដាក់ជូនក្រុមការងារថ្នាក់ជាតិប្រជុំដោះស្រាយ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា: ដើម្បីប្រសិទ្ធិភាពការងារ យើងបានកែសម្រួលរចនាសម្ព័ន្ធការងាររួចហើយ ដូចជា:ប្តូរពីក្រុមលេខាធិការដ្ឋាន មកជាក្រុមជំនួយការ និងបានកែសម្រួលសមាសភាពក្នុងជួរគណៈអភិបាលខេត្ត ដូចជា: ឯកឧត្តម លោកជំទាវ អភិបាលរងខេត្តមកជាអនុប្រធានទី១ ប្រចាំក្រុង ស្រុក រីឯ លោកអភិបាលក្រុង ស្រុក ត្រូវបានតែងតាំងជាអនុប្រធានអចិន្ត្រៃយ៍ តាមបណ្តាក្រុងស្រុក នីមួយៗ តាមរយៈសេចក្តីសម្រេចលេខ ០១៨-០១៩ និង០២០ របស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ខេត្តកំពត ។ ឯកឧត្តម ទេសរដ្ឋមន្ត្រីសង្ឃឹមថា តាមរយៈការកែសម្រួលនេះ ក្រុមការងារនឹងក្តាប់បាន ហើយដោះស្រាយបញ្ហាកាន់តែមានប្រសិទ្ធិភាពបន្ថែមទៀត ។ ឯកឧត្តម ទេសរដ្ឋមន្ត្រីស្នើឱ្យក្រុមការងារប្រើប្រាស់តារាងកំណត់បញ្ហាដែលបានរៀបចំដាក់ឱ្យប្រើប្រាស់រួចហើយ ពីព្រោះតារាងនេះមានលក្ខណៈងាយស្រួល ដើម្បីកំណត់បញ្ហាដោះស្រាយ ដែលឯកឧត្តម ណែនាំថា:ត្រូវបែងចែកជា០៥ មុខសញ្ញា រួមមាន:១ -បញ្ហាត្រូវដោះស្រាយត្រឹមថ្នាក់ភូមិ ឃុំ ២-ថ្នាក់ស្រុក ក្រុង ៣ - និងមន្ទីរជុំវិញខេត្ត ៣ -ថ្នាក់ខេត្ត ៤-ថ្នាក់ក្រសួង រឺចង្កោមក្រសួង ៥-ថ្នាក់រាជរដ្ឋាភិបាល ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យក្រុមការងារថ្នាក់ជាតិ បន្តចុះដឹកនាំធ្វើវេទិកាសាធារណៈឱ្យបានញឹកញាប់បន្តទៀត ជាពិសេសធ្វើជាលក្ខណៈវិលជុំឱ្យបានគ្រប់មូលដ្ឋានគោលដៅរបស់ខ្លួន និងស្នើឱ្យឯកឧត្តមអភិបាលខេត្ត រៀបចំកាលវិភាគការងារច្បាស់លាស់ ដើម្បីឱ្យក្រុមការងារត្រៀមលក្ខណៈសម្បត្តិជាមុន ។

ស្ថិតក្នុងឱកាសនោះដែរ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក៏បានឱ្យប្រធានរដ្ឋាករទឹក ខេត្តកំពត ឡើងបកស្រាយ ជូនអង្គប្រជុំ ស្តីពីកង្វល់របស់ប្រជាពលរដ្ឋរឿងសេវាផ្គត់ផ្គង់ទឹកស្អាត និងប្រធានមន្ទីរសង្គមកិច្ចបកស្រាយពីបញ្ហានិវត្តជន ជាង១០០នាក់ដែលមិនទាន់ទទួលបានប្រាក់សោធននិវត្សន៍ផងដែរ ។